ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១០៣.២៤.រដ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការបន្តទប់ស្កាត់សកម្មភាពអាជីវកម្មរ៉ែមាសអនាធិបតេយ្យ ស្ថិតនៅភូមិសាស្ត្រស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ក្រសួងរ៉ែ និងថាមពល មានកិត្តិយសសូមជម្រាបជូនសាធារណជន អំពីការបន្តប្រតិបត្តិការទប់ស្កាត់សកម្មភាពអាជីវកម្មរ៉ែមាសអនាធិបតេយ្យ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បន្ទាប់ពីបានបើកប្រតិបត្តិការដោះស្រាយទ្រង់ទ្រាយធំ លើទីតាំងអាជីវកម្មរ៉ែមាសអនាធិបតេយ្យនៅភូមិសាស្ត្រភូមិសំពៅលូន ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ក្រសួងរ៉ែ និងថាមពល បានទទួលការស្វាគមន៍ពីប្រជាពលរដ្ឋជាទូទៅ ជាពិសេសពីប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយបងប្អូនប្រជាពលរដ្ឋបានបន្តចូលរួមសហការផ្តល់ព័ត៌មាន អំពីវត្តមានអាជីវកម្មរ៉ែមាសលួចលាក់ខុសច្បាប់ដទៃផ្សេងទៀតនៅក្នុងតំបន់ខាងលើ។ ជាក់ស្តែង គិតត្រឹមថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ ក្រសួងរ៉ែ និងថាមពល បានទទួលព័ត៌មាន និងរកឃើញទីតាំងអាជីវកម្មរ៉ែមាសខុសច្បាប់លួចលាក់ចំនួន ៣ (បី) ទីតាំងបន្ថែមទៀត នៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

បន្ទាប់ពីទទួលបានព័ត៌មានស្តីពីការធ្វើអាជីវកម្មរ៉ែមាសអនាធិបតេយ្យ ក្រសួងរ៉ែនិងថាមពល ដោយមានមន្ទីររ៉ែ និងថាមពល ខេត្តត្បូងឃ្មុំ ជាសេនាធិការ បានសហការជាមួយអាជ្ញាធរដែនដី ចុះពិនិត្យ និងទប់ស្កាត់ ព្រមទាំងបានណែនាំដល់ម្ចាស់ទីតាំងអាជីវកម្មរ៉ែមាសអនាធិបតេយ្យទាំងនោះ អំពីនីតិវិធីច្បាប់និងផលប៉ះពាល់ធ្ងន់ធ្ងរលើសុវត្ថិភាព សុខភាព និងបរិស្ថាន។ បន្ទាប់ពីទទួលបានការណែនាំ ម្ចាស់ទីតាំងទាំងអស់បានស្ម័គ្រចិត្តរុះរើ និងធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពអាជីវកម្មរ៉ែមាសខុសច្បាប់របស់ខ្លួន។

ជាថ្មីម្តងទៀត ក្រសួងរ៉ែនិងថាមពល នឹងបន្តប្តេជ្ញាបញ្ចប់នូវរាល់សកម្មភាពរ៉ែអនាធិបតេយ្យ និងជំរុញឱ្យមានការធ្វើអាជីវកម្មរ៉ែស្របច្បាប់ ដែលនាំមកនូវផលប្រយោជន៍ជាតិជាច្រើនមានជាអាទិ៍ ការបង្កើតឱ្យមានឱកាសការងារនៅនឹងកន្លែង និងប្រយោល ការចូលរួមចំណែកដល់ការបង្កើតប្រភពចំណូលថវិកាជាតិបន្ថែម និងការបំបាត់នូវផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម ព្រមទាំងចូលរួមចំណែកអភិវឌ្ឍន៍សហគមន៍មូលដ្ឋានតាមរយៈការធ្វើអាជីវកម្មរ៉ែប្រកបដោយចីរភាព ដោយមានការគាំទ្រ និងការការពារពីច្បាប់។ ក្នុងន័យនេះ ក្រសួងរ៉ែ និងថាមពល សូមថ្លែងអំណរគុណចំពោះសមត្ថកិច្ចពាក់ព័ន្ធ ដែលបានចូលរួមអនុវត្តយន្តការទប់ស្កាត់អាជីវកម្មរ៉ែអនាធិបតេយ្យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយសូមថ្លែងអំណរគុណចំពោះបងប្អូនប្រជាពលរដ្ឋដែលផ្តល់ទំនុកចិត្ត និងចូលរួមសហការក្នុងយន្តការរបស់ក្រសួងរ៉ែ និងថាមពល។



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

ឆ្លៀតក្នុងឱកាសនេះ ក្រសួងរ៉ែ និងថាមពលសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋបន្តចូលរួមសហការជូនដំណឹងអំពីសកម្មភាពរ៉ែអនាធិបតេយ្យ មកក្រសួងរ៉ែ និងថាមពល តាមរយៈប្រព័ន្ធទូរស័ព្ទលេខ ០៩៥ ៧២៧ ៧២៧ ដើម្បីក្រសួងមានលទ្ធភាពចាត់វិធានការទាន់ពេល។

អាស្រ័យហេតុនេះ សូមសាធារណជន អ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៧កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤

## កម្រងរូបភាព នៃការអនុវត្តយន្តការទប់ស្កាត់សកម្មភាពអាជីវកម្មរ៉ែមាស អនាធិបតេយ្យ នៅក្នុងភូមិសាស្ត្រស្រុកមេមត់ ខេត្តត្បូងឃ្មុំ









លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh








លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh







លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh










លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh